# ក្រុមមេធាវីការពារក្តី អៀង សារី
# IENG SARY DEFENCE TEAM
# EQUIPE DE DEFENSE DE IENG SARY

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 14-Aug-2012, 15:46
CMS/CFO: Sann Rada

**អាង ឧត្តម** និង **Michael G. KARNAVAS**
សហមេធាវីការពារក្តីលោក អៀង សារី
ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០១២

ផ្ញើជូន៖ **Susan LAMB**
មន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូង

ចម្លងជូន៖ **ក្រុមមេធាវីការពារក្តី**

**ការិយាល័យសហព្រះរាជអាជ្ញា**

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

យោង៖ កិច្ចប្រជុំរៀបចំសវនាការនាពេលដ៏ខ្លីខាងមុខ

ជូនចំពោះអ្នកស្រី Lamb,

ដើម្បីឆ្លើយតបទៅនឹងអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងលេខ E218 ចុះថ្ងៃទី ៣ ខែ សីហា ឆ្នាំ ២០១២ ទាក់ទិននឹងកិច្ចប្រជុំរៀបចំសវនាការនាពេលដ៏ខ្លីខាងមុខនេះ យើងខ្ញុំសូមលើកឡើងនូវបញ្ហានានាដូចខាងក្រោម៖

**<u>ថាតើកិច្ចប្រជុំរៀបចំសវនាការនឹងត្រូវរៀបចំជាសាធារណៈ ឬជាសម្ងាត់</u>**

អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងបានលើកឡើងថា កិច្ចប្រជុំរៀបចំសវនាការនាពេលដ៏ខ្លីខាងមុខនឹងត្រូវរៀបចំធ្វើជាសម្ងាត់ "ដោយផ្តោតលើបញ្ហាបច្ចេកទេស"[1]។ យើងខ្ញុំសូមស្នើដោយគោរពដល់

---

[1] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងដែលមានចំណងជើងថា "ការកំណត់កាលបរិច្ឆេទនៃកិច្ចប្រជុំរៀបចំសវនាការដើម្បីជួយដល់ការធ្វើផែនការសម្រាប់ដំណាក់កាលនៃការជំនុំជម្រះដែលនៅសេសសល់ក្នុងសំណុំរឿង ០០២/០១ និងការអនុវត្ត

អង្គជំនុំជម្រះសាលាដំបូងសូមមេត្តាពិចារណាសេចក្តីសម្រេចរបស់ខ្លួនឡើងវិញ ដើម្បីលើកកម្ពស់តម្លាភាព។ បញ្ហានានាដែលនឹងលើកឡើងនៅក្នុងកិច្ចប្រជុំនេះគឺពិតជាបម្រើប្រយោជន៍សាធារណជនទូទៅ និងមិនមែនមានលក្ខណៈបច្ចេកទេសខ្លាំងពេក រហូតសាធារណជនមិនអាចស្វែងយល់បាន ឬមិនឲ្យតម្លៃដល់ការពិភាក្សានេះនោះទេ។ បញ្ហានានាដែលពាក់ព័ន្ធនឹងសាក្សីជាក់លាក់អាចនឹងដោះស្រាយបាន ដោយប្រើរហស្សនាមសាក្សីទាំងនោះ។ ដើម្បីជាប្រយោជន៍ដល់ការបើកទូលាយ និងតម្លាភាព ចៅក្រមនៅតុលាការសហរដ្ឋអាមេរិក Louis Brandeis បានផ្តល់ការកត់សម្គាល់ដែលល្បីរន្ទឺថា "ពន្លឺថ្ងៃគឺជា ... ឱសថដ៏ស័ក្តិសិទ្ធិបំផុតសម្រាប់កម្ចាត់មេរោគ"[2]។ ទោះបីចៅក្រម Brandeis និយាយសំដៅដល់ធុរកិច្ចធនាគារក៏ដោយ ក៏ទស្សិករណ៍នេះសក្តិសមនឹងកិច្ចការរបស់តុលាការដែរ ជាពិសេសគឺ អវតក។ តម្លាភាពមិនត្រឹមតែបង្ហាញឲ្យសាធារណជនបានយល់កាន់តែច្បាស់ពីការងារ ដែលអង្គជំនុំជម្រះសាលាដំបូង/អវតកំពុងធ្វើប៉ុណ្ណោះទេ តែវាក៏ជំរុញឲ្យអ្នកដែលចូលរួមជាមួយអង្គជំនុំជម្រះសាលាដំបូង/អវតក (ចៅក្រម សហព្រះរាជអាជ្ញា មេធាវី) បំពេញកាតព្វកិច្ចរបស់ខ្លួនបានប្រសើរជាងមុន សម្រាប់សាធារណជននៅកម្ពុជា ដែលជាភាគីពាក់ព័ន្ធសំខាន់ជាងគេក្នុងកិច្ចដំណើរការនីតិវិធីនៅ អវតក នេះ។ ដោយសារកេរ្តិ៍ឈ្មោះរបស់ អវតក ត្រូវបានធ្វើឲ្យហ្មងសៅដោយសាររឿងអាស្រូវគ្រប់ប្រភេទ និងឧបាយកលខាងក្រោយឆាកដែលបន្តលេចចេញឲ្យឃើញ (ទោះបីមានការខិតខំបិទបាំង ឬ ទប់ស្កាត់ក៏ដោយ) និងដោយពិចារណាថា នឹងមានការពិភាក្សាដេញដោលគ្នាលើបញ្ហាជាច្រើន ដែលមិនសម្ងាត់នៅក្នុងការប្រជុំសម្ងាត់នោះ និងដោយពិចារណាថា សេចក្តីសម្រេចពីការប្រជុំនេះអាចនឹងធ្វើឲ្យបាត់បង់ការទុកចិត្តពីសាធារណជននោះ យកល្អអង្គជំនុំជម្រះសាលាដំបូងគួរតែរៀបចំកិច្ចប្រជុំរៀបចំសវនាការនាពេលខាងមុខទាំងអស់ ជាសាធារណៈវិញទើបជាការប្រសើរជាង។ បណ្តាម្ចាស់ជំនួយ ក្រុមអ្នកឃ្លាំមើលតុលាការ និងអង្គការសង្គមស៊ីវិលនានាក៏នឹងបានទទួលប្រយោជន៍ផងដែរពីតម្លាភាពនេះ ដែលពិតជាផ្តល់ឱកាសឲ្យពួកគេបានដឹងពីឧបសគ្គនានាដែលពាក់ព័ន្ធនឹងការរៀបចំសវនាការក្នុងសំណុំរឿង ០០២/០១ អនុលោមទៅតាមទម្លាប់អនុវត្ត និងបទដ្ឋានអន្តរជាតិដែលមានចែងក្នុងកិច្ចព្រមព្រៀង ច្បាប់ស្តីពីការបង្កើត អវតក និងវិធានផ្ទៃក្នុង។

## <u>បញ្ហានានាដែលបានស្នើសុំឲ្យបន្ថែមក្នុងរបៀបវារៈនៃកិច្ចប្រជុំរៀបចំសវនាការ</u>

---

វិធានការបន្ថែមដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃសវនាការ" ថ្ងៃទី ៣ ខែ សីហា ឆ្នាំ ២០១២ ឯកសារ E218 ("អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង") ទំព័រ ៦។

[2] Louis D. Brandeis, *លុយរបស់អ្នកផ្សេង (Other People's Money)*, Harper Weekly, ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ១៩១៣។

យើងខ្ញុំមានបញ្ហាតែមួយគត់ ដែលត្រូវស្នើសុំបន្ថែមឲ្យដាក់ក្នុងរបៀបវារៈនៃកិច្ចប្រជុំរៀបចំសវនាការ គឺ៖ បញ្ហានៃភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធីកន្លងមក។ មានឧបទ្ទវហេតុនានាជាច្រើនបានកើតឡើង ក្នុងពេលសវនាការដែលនាំឲ្យយើងខ្ញុំមានកង្វល់ថា សិទ្ធិរបស់កូនក្តីយើងខ្ញុំក្នុងការទទួលបានសវនាការ ប្រកបដោយយុត្តិធម៌អាចនឹងមិនត្រូវបានការពារឲ្យបានពេញលេញទេ។ យើងខ្ញុំបានរៀបចំការពន្យល់ ពិស្តាររួចហើយពីករណីនីមួយៗសម្រាប់លើកឡើងក្នុងកិច្ចប្រជុំរៀបចំសវនាការ។ ឧទាហរណ៍នានារួម មាន៖ **ក**.ការផ្តាច់ឧគ្ឃោសនស័ព្ទជាញឹកញយនៅពេលមេធាវីការពារក្តីកំពុងនិយាយ **ខ**.ចៅក្រមមិនបាន សួរសំណួរដែលអាចជួយដល់ភស្តុតាងដោះបន្ទុក **គ**.ចៅក្រមប្រើសំណួរនាំមុខ ឬសួរសំណួរដែលហាម ឃាត់ភាគីមិនឲ្យប្រើប្រាស់ ដោយគ្រាន់តែប្រើការសម្រេចផ្ទាល់មាត់ **ឃ**.ចៅក្រមមិនបានបង្ហាញសំអាង ហេតុសម្រាប់ចេញសេចក្តីសម្រេចផ្ទាល់មាត់ **ង**.ការណ៍ដែលថា ការសម្រេចផ្ទាល់មាត់ដែលប៉ះពាល់ដល់ ការស្តាប់ភស្តុតាងនេះមិនអាចប្តឹងឧទ្ធរណ៍បានទេ រហូតទាល់តែពេលចេញសាលក្រម ដែលវាហួសពេល នឹងកែតម្រូវនូវកំហុសឆ្គងនានា **ច**.ការណ៍ដែលថា សេចក្តីសម្រេចផ្ទាល់មាត់ជាច្រើនត្រូវបានចេញដោយធ្វើ ឡើងដោយចៅក្រមប្រធានតែម្នាក់ឯង ដោយគ្មានការចូលរួមយោបល់ពីចៅក្រមផ្សេងៗទៀតនៃ អង្គជំនុំជម្រះទាំងមូល និង **ឆ**.ការហាមឃាត់មិនឲ្យសួរសាក្សីនូវសំណួរដែលអាចនាំឲ្យសាក្សីឆ្លើយ ផ្ទុយនឹងអ្វីដែលគាត់បានឆ្លើយពីមុន ឬនាំឲ្យសាក្សី "បាត់ទំនុកចិត្ត"[3]។ ជាជម្រើសផ្សេងទៀត យើងខ្ញុំ សូមស្នើឲ្យមានសវនាការសាធារណៈដាច់ដោយឡែកមួយលើបញ្ហានេះ ដែលភាគីមានឱកាសលើកឡើងនូវ បទបង្ហាញផ្ទាល់មាត់របស់ខ្លួនដោយមានការសារណាជាលាយលក្ខណ៍អក្សរ។

**<u>ចេតនារបស់អង្គជំនុំជម្រះសាលាដំបូងដើម្បីកាត់បន្ថយបញ្ជីឈ្មោះអ្នកជំនាញ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី ក្នុងសំណុំរឿង ០០២/០១</u>**

---

[3] *សូមមើល* ប្រតិចារិក ថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០១២ ឯកសារ E1/10.1 ទំព័រ ៥៤, និងការគូសបញ្ជាក់របស់លោកស្រីចៅក្រម Cartwright ទំព័រ ៦២៖ "វាអាចមានការយល់ច្រឡំគ្នានៅពេលដែលលោកប្រធានឲ្យយោបល់ទៅលើរបៀបដែលលោក Karnavas តាំងសំណួរទៅកាន់សាក្សី។ អង្គជំនុំជម្រះចង់បញ្ជាក់ថា លោកមានសិទ្ធិសួរសំណួរតទល់ និងសំណួរស៊ើបសួរវាជាកាតព្វកិច្ចរបស់លោក។ ក៏ប៉ុន្តែការព្រួយបារម្ភរបស់អង្គជំនុំជម្រះនោះគឺរថា ចៅក្រមវិជ្ជាជីវៈគឺយើងមិនប្រើប្រាស់អារម្មណ៍ថា ដែលយើងសំដែងឲ្យចេញផ្ទាល់ ដូចដែលយើងមើលតាមរយៈខ្សែភាពយន្តអាមេរិកនោះទេ។ នៅក្នុងសាលសវនាការ យើងកុំប្រើចំណុចនេះ។ យើងសូមកោតសរសើរ ប្រសិនបើលោកចងចាំត្រង់ចំណុចនេះ។ សូមអរគុណ"។ ការបញ្ជាក់របស់ចៅក្រម Cartwright ហាក់ដូចជាសង្កត់ធ្ងន់ទៅលើទម្រង់នៃការតាំងសំណួរ ជាជាងវិសាលភាពខ្លឹមសារនៃការសួរសំណួរ។ *សូមមើលផងដែរ* ប្រតិចារឹក ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១២ ឯកសារ E1/99.1 ទំព័រ ៩៥។

ទោះបីបញ្ហានេះនឹងត្រូវដោះស្រាយបានកាន់តែពេញលេញ នៅក្នុងកិច្ចប្រជុំរៀបចំសវនាការក៏ដោយ តែដើម្បីឲ្យយើងខ្ញុំបង្ហាញជំហររបស់ខ្លួនបានច្បាស់ចាប់ពីដំបូងនោះ យើងខ្ញុំសូមគាំទ្រដល់សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការកាត់បន្ថយចំនួនអ្នកជំនាញ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីដែលនឹងត្រូវមកផ្តល់សក្ខីកម្មផ្ទាល់មាត់។ យើងខ្ញុំពិចារណាឃើញថា ការអនុវត្តនេះនឹងជួយពន្លឿនកិច្ចដំណើរការនីតិវិធី។ យើងខ្ញុំសូមស្នើថា អង្គជំនុំជម្រះសាលាដំបូងគួរពិចារណាបន្ថែមទៀតថា តើវាជាការចាំបាច់ទេដែលត្រូវស្តាប់សក្ខីកម្ម "អ្នកជំនាញ" ដែលមានលេខសម្គាល់ TCE-80 និង TCE-65 ដែលបានចាត់តាំងហើយនោះ។ យើងខ្ញុំសូមលើកឡើងថា សក្ខីកម្មរបស់អ្នកជំនាញទាំងពីររូបនេះទំនងជាពុំអាចជួយអង្គជំនុំជម្រះសាលាដំបូងក្នុងការបញ្ជាក់ការពិតបានទេ ជាពិសេស ដោយសារពួកគាត់ពុំមែនជាអ្នកជំនាញ*ពិតប្រាកដ* ហើយសក្ខីកម្មរបស់ពួកគាត់នឹងក្លាយជាការចំណាយពេលឥតប្រយោជន៍ ដោយគ្រាន់តែសក្ខីកម្មដដែលៗ និងបន្ទាប់បន្សំមិនចាំបាច់ - នេះពុំទាន់និយាយដល់ការពិតដែលពួកគាត់មិនមែនជាអ្នកជំនាញផងនៅឡើយទេ។ ប្រសិនបើក្នុងគោលបំណងដើម្បីធ្វើឲ្យនីតិវិធីដំណើរការប្រកបដោយប្រសិទ្ធភាពវិញ អង្គជំនុំជម្រះសាលាដំបូងត្រូវប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួនឲ្យបានប្រសើរ ដោយកាត់បន្ថយនូវរាល់សក្ខីកម្មរបស់សាក្សីទាំងឡាយណា ដែលមិនបានផ្តល់តម្លៃជាភស្តុតាងចំពោះសំណុំរឿង ០០២/០១។

**<u>សំណើសុំសាក្សីថ្មីដែលពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជនក្នុងដំណាក់ទី១ និងទី២</u>**

នៅឯកិច្ចប្រជុំរៀបចំសវនាការ អង្គជំនុំជម្រះសាលាដំបូងបានអញ្ជើញភាគីទាំងអស់ឲ្យកំណត់ចំនួនអ្នកជំនាញ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីដែលខ្លួនចាត់ទុកថា មានសារៈសំខាន់ដល់ការសួរដេញដោលពាក់ព័ន្ធនឹងផ្នែកនៃការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១ និងទី២) នៃសវនាការ។ ដើម្បីឲ្យមានតម្លាភាព (ប្រសិនបើកិច្ចប្រជុំរៀបចំសវនាការត្រូវរៀបចំធ្វើជាសម្ងាត់មែន) និងប្រសិទ្ធភាព យើងខ្ញុំសូមឆ្លៀតឱកាសនេះជូនដំណឹងដល់អង្គជំនុំជម្រះថា យើងខ្ញុំនឹងមិនមានបំណងកោះហៅអ្នកជំនាញ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីបន្ថែមលើបញ្ហានេះទេ។

**<u>លទ្ធភាពដែលអាចលើកឡើងដោយអង្គជំនុំជម្រះសាលាដំបូងក្នុងការរៀបចំសវនាការនៅរាល់ថ្ងៃសុក្រ ជំនួសថ្ងៃពុធវិញ</u>**

ទោះបីបញ្ហាបើកសវនាការនៅរៀងរាល់ថ្ងៃពុធជាជាងនៅថ្ងៃសុក្រ នឹងត្រូវដោះស្រាយនៅឯកិច្ចប្រជុំរៀបចំសវនាការក៏ដោយ តែដើម្បីជូនដំណឹងជាមុន និងដើម្បីពន្លឿនកិច្ចដំណើរការនីតិវិធីផង យើងខ្ញុំសូមឆ្លៀតឱកាសនេះ លើកឡើងនូវជំហររបស់យើងខ្ញុំពាក់ព័ន្ធនឹងបញ្ហានេះ។ ក្រោយពីបានពិភាក្សាជាមួយកូនក្តីយើងខ្ញុំរួចមក យើងខ្ញុំយល់ឃើញថា កាលវិភាគបច្ចុប្បន្នដែលការបើកសវនាការនៅរៀងរាល់ថ្ងៃពុធ

ជាជាងនៅថ្ងៃសុក្រគឺជាការប្រសើរជាង។ កាលវិភាគបច្ចុប្បន្នអាចឲ្យមានពេលកន្លះម៉ោងបន្ថែមទៀតនៅបន្ទប់សវនាការក្នុងមួយសប្តាហ៍។ វាក៏អនុញ្ញាតឲ្យភាគីមានប្រតិចារឹកពេញមួយសប្តាហ៍មុនថ្ងៃចុងសប្តាហ៍ តែបើយើងមានសវនាការនៅថ្ងៃសុក្រវិញ យើងខ្ញុំនឹងមិនបានទទួលប្រតិចារឹកពីសវនាការទាំងនោះទេ រហូតដល់ថ្ងៃច័ន្ទសប្តាហ៍បន្ទាប់។ ជាងនេះទៀត ដើម្បីឲ្យការសួរសំណួរដល់សាក្សីកាន់តែមានប្រសិទ្ធភាព និងដោយសារយើងខ្ញុំមិនអាចចូលប្រើប្រាស់ឃ្លាំងផ្ទុកឯកសាររួម (S-Drive) ពីចម្ងាយបាននោះ វាជាការសំខាន់ដែលយើងត្រូវមានពេលទំនេរនៅថ្ងៃសុក្រ ដើម្បីរៀបចំ និងត្រៀមបញ្ហាផ្សេងៗ ទៀតដែលយើងខ្ញុំមិនអាចដោះស្រាយបានក្នុងពេលដែលកិច្ចដំណើរការនីតិវិធីកំពុងបន្តក្នុងតុលាការ (មេធាវីការពារក្តីពុំមានធនធានមនុស្សដូច កសព ទេ)។

<u>ការប្រមើលទុកជាមុននូវថិរវេលា និងចំនួនទំព័រសម្រាប់សារណាបញ្ចប់ការពិភាក្សាដេញដោល</u>

អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងបញ្ជាក់ថា អង្គជំនុំជម្រះកំពុងតែពិចារណាអំពីការកម្រិតចំនួនទំព័រនៃសារណាបញ្ចប់ការពិភាក្សាដេញដោល និងតម្រូវឲ្យសារណាទាំងនេះត្រូវធ្វើឡើងឲ្យទាន់ពេលកំណត់នៅក្នុងរយៈមួយខែប្រតិទិន គិតចាប់ពីថ្ងៃបញ្ចប់កិច្ចនីតិវិធីនៃការជំនុំជម្រះនៅក្នុងសំណុំរឿង ០០២/០១។ យើងគិតថា ចំនួន ៥០ទំព័រ គឺមិនគ្រប់គ្រាន់ឡើយដើម្បីលើកឡើងនូវរាល់បញ្ហាអង្គហេតុ និងអង្គច្បាប់សំខាន់ៗទាំងអស់ ដែលចាំបាច់សម្រាប់ជួយដល់អង្គជំនុំជម្រះក្នុងការពិភាក្សាសម្រេចនោះទេ។ អនុលោមតាមមាត្រា ៥.៣ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក ការកម្រិតចំនួនទំព័រធម្មតា គឺចំនួន ១០០ទំព័រ ជាភាសាអង់គ្លេស ឬភាសាបារាំង និង ២០០ទំព័រ ជាភាសាខ្មែរ។ ដោយពិចារណាទៅលើសារៈសំខាន់នៃសារណាបញ្ចប់ការពិភាក្សាដេញដោល យើងសូមបញ្ជាក់ដោយក្តីគោរពថាគួរតែមានការបន្ថែមការកម្រិតចំនួនទំព័រនេះ ជាជាងបន្ថយចំនួនទំព័រ ហើយចំនួន ១០០ទំព័រ អាចជាចំនួនមួយសមរម្យ។

យើងយល់ឃើញទៀតថា រយៈពេលកំណត់១ខែ សម្រាប់សារណាបញ្ចប់ការពិភាក្សាដេញដោល គឺមិនគ្រប់គ្រាន់ឡើយ ជាពិសេស នៅពេលដែលពិចារណាអំពីភាពស្មុគស្មាញនៃរឿងក្តីនេះ ចំនួនភស្តុតាងដែលពាក់ព័ន្ធ ធនធានដែលមានកំណត់ ការប្រើប្រាស់ពេលវេលាច្រើនក្នុងត្រៀមរៀបចំកិច្ចដំណើរការនីតិវិធីជារៀងរាល់ថ្ងៃ និងថិរវេលានៃកំណត់ហេតុសវនាការ និងចំនួននៃភស្តុតាងដែលត្រូវបានទទួលយក ដែលមកដល់ពេលនេះមិនទាន់បានដឹងនៅឡើយនោះ។ ជាធម្មតា ប្រសិនបើអង្គភាពបកប្រែភាសា អាចបកប្រែ

បាន*ត្រឹមតែ* ៥ទំព័រ ក្នុងមួយថ្ងៃ រយៈពេលដែលផ្តល់ឲ្យ១ខែនោះ ត្រូវចំណាយអស់រយៈពេល ១០ថ្ងៃ នៃថ្ងៃធ្វើការ (កន្លះខែ) សម្រាប់បកប្រែ ដូច្នេះនៅសល់ *តែពីរ* សប្តាហ៍ប៉ុណ្ណោះដើម្បីធ្វើសេចក្តីព្រាងនូវអ្វីដែលយើងយល់ឃើញថាជាសេចក្តីសន្និដ្ឋានដែលមានសារៈសំខាន់ជាចម្បងនោះ។ យើងយល់ឃើញថា រយៈពេលបីខែប្រតិទិន គឺជាពេលវេលាមួយដ៏សមរម្យ។ ជាក់ស្តែង ប្រសិនបើការកម្រិតចំនួនទំព័រត្រូវបានបន្ថែមដូចដែលបានស្នើឡើងនោះ ទោះបីជាមិនចាំបាច់ក៏ដោយ ត្រូវតែមានបន្ថែមពេលវេលាឲ្យបានគ្រប់គ្រាន់សម្រាប់ការបកប្រែផងដែរ។ យើងអះអាងថា ប្រសិនបើភាគីត្រូវដាក់សារណាបញ្ចប់ការពិភាក្សាដេញដោលដែលមានលក្ខណៈទូលំទូលាយ ច្បាស់លាស់ និងមានសារៈសំខាន់ នោះគួរតែមានការផ្តល់ឲ្យរយៈពេលបីខែ រួមជាមួយនឹងរយៈពេលមួយខែបន្ថែមទៀត ដើម្បីរៀបចំសម្រាប់សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល។ ថិរវេលាដែលបានស្នើឡើងនេះ គឺស្របជាមួយនឹងបទដ្ឋាន និងការកំណត់ពេលវេលាដែលផ្តល់ជូននៅឯតុលាការមិនអចិន្ត្រៃយ៍ និងតុលាការអន្តរជាតិនានាសម្រាប់សំណុំរឿងដែលមានទំហំធំដូចសំណុំរឿង ០០២/០១។

## <u>សំណើសុំចូលមើលឯកសារក្នុងឃ្លាំងផ្ទុកឯកសាររួមពីចម្ងាយ (S-Drive)</u>

អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងហាក់ដូចជាលើកឡើងដោយប្រយោលថា អង្គជំនុំជម្រះសាលាដំបូងពុំមែនជាអ្នកសម្រេច ថាតើភាគីត្រូវបានផ្តល់ការអនុញ្ញាតឲ្យចូលមើលឯកសារនៅក្នុងឃ្លាំងផ្ទុកឯកសាររួមពីចម្ងាយ ឬយ៉ាងណានោះឡើយ។ ការពិភាក្សាក្រៅផ្លូវការរបស់យើងជាមួយនឹងការិយាល័យរដ្ឋបាលបង្ហាញថា វាមិនមែនដូច្នេះឡើយ។ តាមពិត មានការជូនព័ត៌មានមកយើងថា ដោយសារតែការបារម្ភអំពីសន្តិសុខតាមការយល់ឃើញនោះ ការិយាល័យរដ្ឋបាលនឹងផ្តល់ឲ្យមានការចូលមើលឯកសារពីចម្ងាយបាន ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងចេញដីការបង្គាប់អនុញ្ញាតឲ្យភាគីចូលមើលឯកសារពីចម្ងាយ។ ដូច្នេះ ដំណោះស្រាយទៅលើបញ្ហានេះគឺច្បាស់លាស់ណាស់៖ អង្គជំនុំជម្រះសាលាដំបូងចាំបាច់ត្រូវចេញដីការបង្គាប់បែបនេះ ប្រសិនបើអង្គជំនុំជម្រះមានបំណងចង់ឲ្យភាគីចូលមើលឯកសារនៅក្នុងឃ្លាំងផ្ទុកឯកសាររួមពីចម្ងាយ។ ការបង្គាប់ឲ្យភាគីដោះស្រាយជាមួយនឹងការិយាល័យរដ្ឋបាល ចំណាត់ការមិនសមស្របនោះទេ។

ដើម្បីជាប្រយោជន៍ដល់កំណត់ហេតុ វាសមនឹងមានការគូសបញ្ជាក់ ដោយក្តីសោកស្តាយផងដែរថា អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ហាក់ដូចជាស្តីបន្ទោសដល់មេធាវីការពារក្តីចំពោះការពិតដែលថា ចៅក្រម Cartwright មិនមានការជួបពិភាក្សាជាទៀងទាត់ជាមួយនឹងអនុប្រធានការិយាល័យរដ្ឋបាលតទៅទៀតឡើយ ដែលតាមការសន្និដ្ឋានដោយសារតែបញ្ហានៃការប្រាស្រ័យទាក់ទងរវាង*ភាគីតែម្ខាង*

ត្រូវបានលើកឡើងដោយមេធាវីការពារក្តី និងដោយសារតែមានការដាក់សារណានានាសម្រាប់ប្តឹងជិតចិត្ត។ ដូចដែលយើងបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងសេចក្តីសន្និដ្ឋានរបស់យើង បញ្ហាជាមួយនឹងកិច្ចប្រជុំទាំងនេះ គឺជាបញ្ហាដែលថា ចៅក្រម Cartwright ជួបពិភាក្សាជាមួយនឹងអនុប្រធានការិយាល័យរដ្ឋបាល និង *សហព្រះរាជអាជ្ញាអន្តរជាតិ* ត្រូវបានគេសន្មតថាដើម្បីដោះស្រាយបញ្ហារដ្ឋបាល (តាមការសន្មត ដោយសារតែយើងមិនដែលទទួលបានព័ត៌មានណាមួយឡើយ អំពីអ្វីដែលត្រូវបានកំពុងពិភាក្សានោះ) ដោយមានចេតនាយ៉ាងច្បាស់ក្រឡែតមិនដាក់បញ្ចូលមេធាវីការពារក្តី និងអង្គភាពគាំពារការការពារក្តី (DSS) - ផ្នែករដ្ឋបាលនៅក្នុង អ.វ.ត.ក ដែលដោះស្រាយបញ្ហានានាដែលប៉ះពាល់ដល់ក្រុមមេធាវីការពារក្តី (និងជនជាប់ចោទ) នីមួយៗ និងជារួម។ និយាយត្រង់ទៅ គ្មានអ្វីរាំងអង្គជំនុំជម្រះសាលាដំបូង ឬតំណាងរបស់ខ្លួន គឺចៅក្រម Cartwright ឬចៅក្រមផ្សេងៗទៀត មិនឲ្យពិគ្រោះជាមួយនឹងអនុប្រធានការិយាល័យរដ្ឋបាល ពាក់ព័ន្ធនឹងបញ្ហានៃការចូលមើលឯកសារនៅក្នុងឃ្លាំងផ្ទុកឯកសាររួមពីចម្ងាយនោះឡើយ។ ប្រសិនបើ កសព ត្រូវបានដាក់បញ្ចូលនៅក្នុងការប្រាស្រ័យទាក់ទងបែបនេះ យើងយល់ឃើញថា វាជាការត្រឹមត្រូវ និងសមហេតុផលដែលត្រូវដាក់បញ្ចូល DSS (ឬតំណាងរបស់ក្រុមមេធាវីការពារក្តី) និងដើមបណ្តឹងរដ្ឋប្បវេណីផងដែរ។ វិធីសាស្ត្របែបនេះ គឺដើម្បីបញ្ចៀសនូវការកើតមានអំពើខុសឆ្គងណាមួយ និងអាចឲ្យភាគីទាំងអស់បញ្ចេញយោបល់ និងអាចឲ្យភាគីទាំងអស់ចូលរួមក្នុងការស្វែងរកដំណោះស្រាយគួរជាទីពេញចិត្ត។ ពិតណាស់ ដូចដែលបានគូសបញ្ជាក់ខាងលើ វាទំនងជាបង្ហាញថា ការពិភាក្សា ឬការពិគ្រោះយោបល់ជាមួយនឹងការិយាល័យរដ្ឋបាល នឹងមិនមានប្រយោជន៍អ្វីទៀតទេ។ - ឥឡូវនេះ បញ្ហាគឺស្ថិតនៅលើអង្គជំនុំជម្រះសាលាដំបូងទាំងស្រុង និងផ្ទាល់មុខ។ ប្រសិនបើពុំមានការចេញដីកាបង្គាប់ទៅការិយាល័យរដ្ឋបាលនោះទេ នោះក៏គ្មាននរណានឹងមិនអាចធ្វើអ្វីបានឡើយដែរ។ ដោយសារតែហេតុផលនេះហើយ ដែលមេធាវីការពារក្តីបានដាក់សារណាជាលាយលក្ខណ៍អក្សរដោយស្នើសុំឲ្យមានសវនាការមួយ ដែលមានតំណាងការិយាល័យរដ្ឋបាលអាចឡើងមកពន្យល់ជាសាធារណៈអំពីហេតុផលរបស់ពួកគាត់ ក្នុងការមិនអនុញ្ញាតឲ្យចូលមើលឯកសារពីចម្ងាយនោះ និងធ្វើការពន្យល់ថាស្ថិតក្រោមកាលៈទេសៈអ្វីដែលពួកគាត់ត្រូវតែធ្វើយ៉ាងដូច្នេះ[4]។

---

[4] សំណើរបស់លោកអៀង សារី សុំឲ្យមានកិច្ចប្រជុំរៀបចំសវនាការផ្លូវការមួយ ដើម្បីពិភាក្សាពីលទ្ធភាពនៃការចូលប្រើប្រាស់ឃ្លាំងផ្ទុកឯកសាររួមពីចម្ងាយ (S-Drive) ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១២ ឯកសារ E207។ សូមមើលផងដែរ ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងសំណើរបស់អៀង សារី ស្នើសុំឲ្យមានការប្រជុំរៀបចំសវនាការមួយ ដើម្បីពិភាក្សាពីលទ្ធ ភាពនៃការអនុវត្តការចូលបើកមើលឯកសារនៅក្នុង S-Drive ពីចម្ងាយ ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២ ឯកសារ E207/1 ដែលនៅក្នុងនោះ កសព បានយល់ស្រប និងបានគាំទ្រសំណើរបស់យើង។ អាចនិយាយបានថា បញ្ហានៃការបើកមើលឯកសារពីចម្ងាយត្រូវបានលើកឡើងពីដំបូងក្រៅផ្លូវការ នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង កាលពីជាងប្រាំពីរខែ

នេះគឺជាឧទាហរណ៍មួយទៀតថាហេតុអ្វីបានជាតម្លាភាពមានសារៈសំខាន់ចំពោះកិច្ចដំណើរការនីតិវិធី។ ឱកាសបែបនេះគឺជាវេទិកាមួយសម្រាប់អង្គជំនុំជម្រះស្វែងរកដំណោះស្រាយ ក្នុងខណៈដែលខ្លួនកំពុងប្រឈមនឹងអំណះអំណាងដែលមិនសមហេតុផល និងទឡ្ហីករណ៍ដែលមានវិការៈនានា។

## <u>ការកំណត់កាលបរិច្ឆេទថ្មីសម្រាប់ដាក់ពាក្យសុំឲ្យទទួលយកឯកសារថ្មី</u>

យើងមានការព្រួយបារម្ភ អំពីការកំណត់កាលបរិច្ឆេទថ្មីក្នុងការដាក់សំណើសុំឲ្យទទួលយកឯកសារថ្មី[5]។ អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងបញ្ជាក់ថា "ដើម្បីឲ្យពាក្យសុំនោះដាក់ទាន់ពេលវេលាកំណត់ ពាក្យសុំដាក់ឯកសារថ្មីៗនៅចំពោះមុខអង្គជំនុំជម្រះដែលពាក់ព័ន្ធនឹងសាក្សី អ្នកជំនាញ ឬដើមបណ្តឹងរដ្ឋប្បវេណី ដែលគ្រោងនឹងមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ <u>ត្រូវ</u>ធ្វើឡើងយ៉ាងហោចណាស់ឲ្យបានពីរសប្តាហ៍ មុនពេលបុគ្គលទាំងនេះមកផ្តល់សក្ខីកម្ម។ សំណើសុំអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ដែលបានដាក់នៅក្នុងនាទីចុងក្រោយ <u>នឹង</u>ត្រូវបដិសេធចោល"[6]។ វិធានតឹងរ៉ឹងបែបនេះ អាចនាំឲ្យអង្គជំនុំជម្រះសាលាដំបូងពុំធ្វើការពិចារណាអំពីភ័ស្តុតាងបញ្ជាក់ និងភ័ស្តុតាងពាក់ព័ន្ធនៅក្នុងការស្វែងរកការពិតនោះ។ ប្រសិនបើភ័ស្តុតាងមានការពាក់ព័ន្ធ មានការបញ្ជាក់ និងត្រូវបានច្បាប់អនុញ្ញាតនោះ ភ័ស្តុតាងនោះនឹងជួយដល់អង្គជំនុំជម្រះសាលាដំបូង ហេតុដូច្នេះ ភ័ស្តុតាងនោះគួរតែត្រូវបានទទួលយក។

## <u>តារាងឯកសារសវនាការប្រចាំថ្ងៃ (Daily Trial Documents Interface)</u>

យើងខ្ញុំយល់ស្របជាមួយអង្គជំនុំជម្រះដែលថា ភាគីខ្លះបានបំពានលើការប្រើប្រាស់តារាងឯកសារសវនាការប្រចាំថ្ងៃ ដោយដាក់ឯកសារចំនួនដ៏ច្រើនសន្ធឹកសន្ធាប់។ ប្រការនេះធ្វើឲ្យតារាងឯកសារសវនាការប្រចាំថ្ងៃ ពុំមានប្រយោជន៍។ ទោះជាយ៉ាងណាក្តី យើងខ្ញុំពិតជាសង្ឃឹមថា អង្គជំនុំជម្រះសាលាដំបូងនឹងអនុញ្ញាតឲ្យភាគីដាក់ឯកសារពី ៥ ទៅ ១០ សម្រាប់សាក្សីម្នាក់ នៅពេលសាក្សីជំនាញមកផ្តល់សក្ខីកម្ម។

---

កន្លងទៅ និងត្រូវបានលើកឡើងជាផ្លូវការ កាលពីជិតពីរខែកន្លងទៅ។ វាបង្ហាញឲ្យឃើញថា អស់រយៈពេលជិតមួយឆ្នាំ បញ្ហាដែលត្រូវបានសន្និដ្ឋានថាជាផ្នែកសន្តិសុខ (ដែលមិនកើតមានឡើយនៅឯតុលាការ ICTY ឬតុលាការ ICTR ដែលប្រើប្រាស់បច្ចេកវិជ្ជា ដូចគ្នានឹង អវតក នេះ) នៅតែជាឧបសគ្គផ្តាច់មុខ។

[5] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ទំព័រ ៦។

[6] ដូចយោងខាងលើ (សេចក្តីបញ្ជាក់បន្ថែម)។

យើងខ្ញុំក៏ស្នើសុំជូនជាយោបល់ថា តារាងឯកសារសវនាការប្រចាំថ្ងៃ គួរតែរៀបចំឡើងឲ្យបានងាយស្រួលដល់អ្នកប្រើប្រាស់ ដោយបែងចែកដាច់ពីគ្នាពីសាក្សីម្នាក់ទៅសាក្សីម្នាក់ទៀត។ នាពេលបច្ចុប្បន្ននេះ មានការលំបាកក្នុងការបែងចែកថា តើឯកសារណាមួយសម្រាប់សាក្សីរូបណា នៅពេលមានសាក្សីច្រើននាក់មានវត្តមានក្នុងថ្ងៃតែមួយនោះ។

យើងខ្ញុំសង្ឃឹមថា ព័ត៌មានដែលបានផ្តល់ជូន និងបញ្ហានានាដែលបានលើកឡើងខាងលើនឹងជួយដល់អង្គជំនុំជម្រះសាលាដំបូងក្នុងការរៀបចំរបៀបវារៈស្តាពរ សម្រាប់កិច្ចប្រជុំរៀបចំសវនាការនាពេលដ៏ខ្លីខាងមុខ។

សូមអ្នកស្រីទទួលនូវការរាប់អានពីយើងខ្ញុំ។

**អាង ឧត្តម** **Michael G. KARNAVAS**

សហមេធាវីការពារក្តីលោក អៀង សារី